## តើអ្វីទៅជា DELF Prim ?

គឺសញ្ញាប័ត្រសិក្សាភាសាបារាំងជាផ្លូវការដែលចេញដោយក្រសួងអប់រំជាតិបារាំង មានពកម្រិត ៖ A1.1, A1និង A2 ដែលស្របទៅនឹងក្របខណ្ឌអឺរ៉ុបរួមជាមូលដ្ឋានយោងសម្រាប់ភាសា (CECR)។ សញ្ញាប័ត្រនេះគឺវាសមស្របទៅនឹងកូនសិស្សថ្នាក់បឋមសិក្សា។ វាមិនមានការបង់ប្រាក់អ្វីទាំងអស់។



## ហេតុអ្វីចាំបាច់ត្រូវមានសញ្ញាប័ត្រនេះ?

- ធ្វើឲ្យមានសុពលភាព និងផ្ញើវិញ្ញាបនបត្រទៅលើសមត្ថភាពការប្រើប្រាស់ភាសាបារាំង
- ទទួលបានរង្វាន់ដោយសារការងាររបស់ខ្លួននៅសាលាបារាំង
- មានទម្លាប់ក្នុងការប្រឡងយកសញ្ញាប័ត្រតាំងពីដំបូងនៃការសិក្សាភាសាបារាំងរបស់ខ្លួន

វាគឺជាចំណុចដ៏ល្អបំផុតមួយសម្រាប់អនាគតកូនរបស់លោកអ្នក ៖ កម្រិត DELF B2 នឹងតម្រូវឲ្យមានជាចាំបាច់គ្រប់សិស្សានុសិស្សណាដែលមានបំណងចង់ចូលសិក្សានៅក្នុងមហាវិទ្យាល័យបារាំង ឬមហាវិទ្យាល័យដែលប្រើប្រាស់ភាសាបារាំង ហើយសញ្ញាប័ត្រខាងលើនេះ វាក៏នឹងមានតម្លៃផងដែរប្រសិនបើនៅក្នុងករណីស្វែងរកការងារធ្វើក្នុងមជ្ឈដ្ឋានដែលប្រើប្រាស់ភាសាបារាំង។

## កម្រិតណាមួយ? A1 ឬ A2?

យោងទៅតាមកម្មវិធីអប់រំរបស់សាលា ដំណើរនៃការសិក្សា និងលទ្ធផលនៃការហ្វឹកហាត់ កូនរបស់លោកលោកស្រីនឹងទទួលបានកម្រិត A1 ឬកម្រិតA2។



## ថ្ងៃប្រឡង

កូនរបស់លោក លោកស្រីនឹងប្រឡងវិញ្ញាសារួមមួយដែលធ្វើការវាយតម្លៃលើពសមត្ថភាព (សមត្ថភាពការស្តាប់ សមត្ថភាពការយល់អត្ថបទ និងសមត្ថភាពការសរសេរ) និងវិញ្ញាសាការនិយាយផ្ទាល់មាត់។

| ប្រភេទវិញ្ញាសា DELF Prim A1 / A2 | រយៈពេល | ពិន្ទុ |
|---|---|---|
| **សមត្ថភាពការស្តាប់ (ស្តាប់) – A1 និង A2**<br>ឆ្លើយនឹងកម្រងសំណួរលើឯកសារសំឡេងខ្លីៗពឬ៥ឯកសារសំឡេងដែលនិយាយអំពីសកម្មភាពជីវិតប្រចាំថ្ងៃ(ស្តាប់ពីរដង)។  | ២០នាទី(A1)<br>២៥នាទី(A2) | /២៥ |
| **សមត្ថភាពការយល់អត្ថបទ (អាន) – A1 និង A2**<br>ឆ្លើយនឹងកម្រងសំណួរលើឯកសារជាអត្ថបទខ្លីៗងាយៗ ៣ ឬ៤អត្ថបទ ដែលនិយាយអំពីសកម្មភាពជីវិតប្រចាំថ្ងៃ។  | ៣០នាទី<br>(A1 et A2) | /២៥ |
| **សមត្ថភាពការសរសេរ (សរសេរ)** <br>មានលំហាត់២ ៖<br>A1 • បំពេញឯកសារខ្លីៗ និងឯកសារជាទម្រង់បែបបទ<br>• សរសេរឃ្លាងាយៗ (លិខិតជូនពរខ្លីៗ សារ រឿងខ្លីៗ -ល-) ដែលនិយាយអំពីសកម្មភាពជីវិតប្រចាំថ្ងៃ។<br>A2 • ការសរសេរអំពីសំណេរសង្ខេបខ្លីៗចំនួន២ ៖<br>• ពណ៌នាអំពីព្រឹត្តិការណ៍ ឬបទពិសោធន៍ផ្ទាល់ខ្លួន<br>• សរសេរក្នុងគោលបំណងអញ្ជើញ អរគុណ សាកសួរ ប្រាប់ព័ត៌មាន -ល- (លិខិតជូនពរខ្លីៗ សំបុត្រ) | ៣០នាទី (A1)<br>៤៥នាទី (A2) | /២៥ |
| **សមត្ថភាពការនិយាយ (និយាយ/សន្ទនា)** <br>វិញ្ញាសាមានពដំណាក់កាល ៖<br>១-A1 និងA2 ៖ ការសម្ភាសអមជាមួយនឹងសំណួរ (ឆ្លើយនឹងសំណួរដែលទាក់ទងទៅនឹងខ្លួនឯង គ្រួសារ និងបរិស្ថានជុំវិញខ្លួន)<br>២-A1 ៖ រៀបរាប់ និងនិយាយឆ្លើយឆ្លងផ្លាស់ប្តូរគ្នាអំពីរូបភាពមួយ<br>A2 ៖ ការនិយាយបញ្ចេញគំនិតផ្ទាល់ខ្លួន (ការបង្ហាញពីគំនិត ឬមតិផ្ទាល់ខ្លួនទៅតាមប្រធានបទមួយដែលបានជ្រើសរើស)<br>៣-A1 និងA2 ៖ ការធ្វើការសន្ទនា (ការសំដែង និងធ្វើការសន្ទនាពីប្រធានបទមួយដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃ) | ៥-៧នាទី(A1)<br>៦-៨នាទី(A2) | /២៥ |

ពេលវេលាសរុបរបស់វិញ្ញាសារួម A1 ៖ ១ម៉ោង ២០នាទី

ពេលវេលាសរុបរបស់វិញ្ញាសារួម A2 ៖ ១ម៉ោង ៤០នាទី

ពិន្ទុសរុបគឺ ១០០ពិន្ទុ

ពិន្ទុទាបបំផុតដែលតម្រូវឲ្យបានដើម្បីទទួលបានសញ្ញាប័ត្រគឺ ៖ ៥០/១០០

ពិន្ទុទាបបំផុតដែលតម្រូវឲ្យបានក្នុងវិញ្ញាសានីមួយៗគឺ ៖ ៥/២៥

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **Katy Jacques : katy.jacques@lfrd.net** សូមអរគុណ